# សេចក្តីថ្លែងការណ៍រួម
# ស្តីពី
# ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប សម្រាប់ឆ្នាំ២០២៤

## ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២៣

យើងខ្ញុំជាសហជីព តំណាងកម្មករនិយោជិត អង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិ ធ្វើការលើវិស័យ សិទ្ធិការងារ និងសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា សូមចូលរួមសម្តែងនូវការខកចិត្តជាខ្លាំង ដែលកម្មករនិយោជិតពុំអាចទទួលបានប្រាក់ឈ្នួលអប្បបរមា ២១៣ ដុល្លារក្នុងមួយខែ នៅឆ្នាំ២០២៤។ កន្លងមកដំណើរក្នុងការចរចាជាត្រីភាគី ក្រុមសហជីពដែលឯករាជ្យ តែងតែទាញយកទន្លឹករណ៍ និងលើកយកអំណះអំណាង ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យទាំង ៧ ចំណុច ដែលដាក់ចេញដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មកធ្វើបទបង្ហាញ។ ស្រដៀងគ្នានេះដែរ ភាគីពាក់ព័ន្ធនៃក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមាបានទទួលស្គាល់ថា ចំណូលកម្មករធ្លាក់ចុះ អតិផរណាកើនឡើង ដែលធ្វើឲ្យកម្មករជួបបញ្ហាលំបាកកាន់តែខ្លាំងឡើង។

ថ្មីៗនេះ របកគំហើញនៃការសិក្សាស្រាវជ្រាវដោយក្រុម អង្គការជាតិ អន្តរជាតិ និងក្រុមសហជីពឯករាជ្យ បង្ហាញពីការថយចុះប្រាក់ចំណូល ការកើនឡើងនៃការចំណាយលើការរស់នៅ និងកំណើនបំណុល នៅក្រោយវិបត្តិកូវីដ-១៩[1]។ ការរកឃើញបានបង្ហាញថា កម្មករភាគច្រើនជំពាក់បំណុលក្នុងអំឡុងពេលបិទខ្ទប់ដោយសារវិបត្តិកូវីដ-១៩ ហើយពួកគេមិនមានលទ្ធភាពសងបំណុលនោះទេ។ ក្រៅពីនេះ លទ្ធផលក៏បានបង្ហាញផងដែរថា ចំណូលជាក់ស្តែង រួមទាំងប្រាក់ថែមម៉ោង របស់កម្មករជាច្រើន មានការថយចុះ ខណៈដែលការចំណាយក្នុងការរស់នៅ កើនឡើងដោយសារអតិផរណា។ លទ្ធផលសំខាន់ៗនេះ គឺផ្អែកតាមការប្រៀបធៀបការសិក្សាអង្កេតដែលធ្វើឡើងដោយ CNV International, សម្ព័ន្ធប្រាក់ឈ្នួលអាស៊ី (AFWA), មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (រួមមានសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា (CCAWDU) និងសម្ព័ន្ធសហជីពកម្ពុជា (CATU) ក្នុងឆ្នាំ ២០២២ និងឆ្នាំ ២០២៣។ ការសិក្សានីមួយៗ បានរំលេចទិដ្ឋភាពផ្សេងៗនៃភាពលំបាកលំបិនផ្នែកសេដ្ឋកិច្ចរបស់កម្មកររោងចក្រកាត់ដេរកម្ពុជា។ ការសំយោគលទ្ធផលរកឃើញទាំងនេះ បានផ្តល់ទិដ្ឋភាពរួមដែលបញ្ជាក់ពីភាពចាំបាច់នៃការដំឡើងប្រាក់ឈ្នួលឲ្យបានច្រើន នៅក្នុងឧស្សាហកម្មកាត់ដេរកម្ពុជាមុនការចរចាប្រាក់ឈ្នួលអប្បបរមាថ្នាក់ជាតិ ឆ្នាំ ២០២៣។ ការសិក្សាស្រាវនេះក៏បានជំរុញទៅភាគីពាក់ព័ន្ធរួមទាំង ក្រុមហ៊ុនអ្នកបញ្ជាទិញ និយោជក និង រាជរដ្ឋាភិបាលក្នុងការធ្វើកំណែទម្រង់ប្រាក់ឈ្នួលកម្មកនៅក្នុងវិស័យវាយនភណ្ឌកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរជាបន្ទាន់។

[1] Evidence of workers in distress: Declining income, rising living costs, and spiralling debt post-covid – Center for Alliance of Labor and Human Rights (central-cambodia.org)

ដោយផ្អែកលើអំណះអំណាង និងទស្សីករណ៍ខាងលើ យើងខ្ញុំជាសហជីព តំណាងកម្មករនិយោជិត ស្នើសុំទៅកាន់រាជរដ្ឋាភិបាលពិចារណាលើចំណុចដូចខាងក្រោម ៖

១. ស្នើដំឡើងប្រាក់ឈ្នួលអប្បបរមាឲ្យបាន ២១៣ ដុល្លារក្នុងឆ្នាំ២០២៤។

២. ពិចារណារយៈពេលខ្លីក្នុងការដំឡើងប្រាក់ឈ្នួលចន្លោះ ៣០០ ទៅ ៥០០ ដុល្លារ សម្រាប់រយៈពេលវែង។

៣. បង្កើនកម្មវិធីលើកកម្ពស់ របបអាហារសម្រាប់កម្មករនិយោជិត ដោយស្នើសុំនិយោជកផ្តល់អាហារថ្ងៃត្រង់ ឬប្រាក់ចំនួន ១ ដុល្លារ អាមេរិក ក្នុងមួយថ្ងៃ ជូនដល់កម្មករនិយោជិត។

៤. បង្ហាញកម្រិតចំណេញរបស់និយោជកប្រកបដោយតម្លាភាពតាមរយៈការចរចារ (អនុសញ្ញារួម) នៅថ្នាក់វិស័យ។

៥. កាត់បន្ថយអតិផរណាផ្នែកចំណីអាហារ ថ្លៃសាំង និងការអនុវត្តច្បាប់លើផ្ទះជួលឲ្យមានប្រសិទ្ធភាព។

៦. សម្រួលរចនាសម្ព័ន្ធប្រាក់ឈ្នួល និងប្រាក់រង្វាន់ និងអត្ថប្រយោជន៍ផ្សេងៗទៅក្នុងប្រាក់ឈ្នួលអប្បបរមា។

៧. ដាក់ចេញនូវវិធានការបន្ទាន់ក្នុងការពិនិត្យ និងពិចារណាក្នុងការទម្លាក់ថវិកាជាតិដើម្បីសម្រួលលក្ខខណ្ឌបំណុល (ពន្យារការបង់ប្រាក់ដើម និង និងការប្រាក់)។

៨. បន្តបញ្ចុះតម្លៃទឹកភ្លើង និងតបណ្តាញទឹកភ្លើងបន្ថែមដល់ផ្ទះជួលរបស់កម្មករនិយោជិតនៅកន្លែងដែលមិនទាន់បានតភ្ជាប់។

៩. ស្នើក្រុមហ៊ុនត្រូវផ្តល់រថយន្តដឹកជញ្ជូនកម្មករ ដែលមានលក្ខណៈបច្ចេកទេសត្រឹមត្រូវ ដោយឥតគិតថ្លៃ ឬបន្ថែមប្រាក់លើមធ្យោបាយធ្វើដំណើរ ឬថ្លៃស្នាក់នៅរបស់កម្មករចំនួន ១៥ ដុល្លារ អាមេរិក ក្នុងមួយខែ។

១០. កំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតលើវិស័យផ្សេងទៀត ដូចកម្មករនិយោជិតនៅក្នុងវិស័យកាត់ដេរ។

១១. ស្នើបេឡាជាតិរបបសន្តិសុខសង្គមពង្រីកការចុះបញ្ជីសមាជិក និងពង្រឹងសេវារបបសន្តិសុខសង្គម ឲ្យមានគុណភាពល្អ ជាពិសេសជំរុញឲ្យអធិការកិច្ចចុះត្រួតពិនិត្យ និងផាកពិន័យឲ្យបានធ្ងន់ធ្ងរ ចំពោះក្រុមហ៊ុនណាដែលបានលាក់ចំនួនកម្មករនិយោជិត និងមិនបានចុះបញ្ជីកម្មករ និងជំរុញឲ្យក្រសួងសុខាភិបាល ចាត់វិធានការឲ្យបានធ្ងន់ធ្ងរ ចំពោះគ្រូពេទ្យ ឬមន្ទីរពេទ្យណាមួយ ដែលមានការរើសអើង និងមិនបានគោរពតាមក្រមសីលធម៌ និងវិជ្ជាជីវៈព្យាបាលអ្នកជំងឺ។

១២. ស្នើបេឡាជាតិរបបសន្តិសុខសង្គមចុះបញ្ជីជូនកម្មករនិយោជិត និងប្រជាពលរដ្ឋដែលមានអាយុលើសពី ៦០ ឆ្នាំ ឲ្យទទួលបានរបបថែទាំសុខភាព និងរបបប្រាក់សោធន៍ដូចកម្មករនិយោជិតទូទៅដែរ។

១៣. ស្នើសុំបន្តផ្តល់បណ្ណមូលនិធិសមធម៌ជូនកម្មករនិយោជិតក្រៅប្រព័ន្ធឡើងវិញ ដោយមិនចាំបាច់បញ្ជាក់មុខរបរពីអាជ្ញាធររាជធានី-ខេត្តឡើយ។

១៤. ស្នើសុំឲ្យក្រុមហ៊ុនទទួលយកថ្នាក់ដឹកនាំសហជីពដែលបានបញ្ឈប់ និងបញ្ចប់កិច្ចសន្យាការងារឲ្យចូលធ្វើការងារវិញ រួមទាំងសងនូវប្រាក់រំលឹក ព្រមទាំងទម្លាក់ចោលរាល់ការចោទប្រកាន់នានា ក្នុងប្រព័ន្ធតុលាការ និងដោះស្រាយវិវាទដែលជាប់គាំងកន្លងមក។

១៥. ស្នើសុំដាក់ពិន័យឲ្យបានធ្ងន់ធ្ងរ និងលុបបំបាត់ចំពោះក្រុមហ៊ុនម៉ៅការបន្តដែលខុសច្បាប់។

១៦. ស្នើសុំឧបត្ថម្ភសាច់ប្រាក់ឲ្យបានចំនួន ៥០ % នៃប្រាក់ឈ្នួលគោល និងពីរដ្ឋាភិបាលតាមរយៈមូលនិធិជំនួយសង្គមដល់កម្មករនិយោជិតក្នុងវិស័យកាត់ដេរ និងកម្មករនិយោជិតក្នុងវិស័យផ្សេងទៀត ដែលព្យួរកិច្ចសន្យាការងារ និងបាត់បង់ការងារ។

ថ្ងៃសុក្រ ១៥កើត ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២៣

**សេចក្តីថ្លែងការណ៍នេះ គាំទ្រដោយ៖**

១. សម្ព័ន្ធសហជីពកម្ពុជា (CATU)
២. សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា (CCAWDU)
៣. មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (CENTRAL)
៤. សហព័ន្ធសហជីពសេរីកម្មករ នៃព្រះរាជាណាចក្រកម្ពុជា (FTUWKC)
៥. សហព័ន្ធសហជីពសេរីឯករាជ្យ (FUFI)
៦. សហព័ន្ធសហជីពឯករាជ្យ (INTUFE)
៧. សហភាពការងារកម្ពុជា (CLC)
៨. សម្ព័ន្ធសហជីពចលនាកម្មករ (CUMW)
៩. សហពន្ធ័សហជីពឥទ្ធិពលការងារ (FULI)
១០. សហព័ន្ធសហជីពកម្ពុជាឯករាជ្យ ( CITUFED)
១១. សម្ព័ន្ធប្រាក់ឈ្នួលអាស៊ី (AFWA)